**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ល.ស/លេខ ០៩.០៩៣/០៩ គ.ជ.ប.អគ្គ.ពស**

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩

# សន្និសីទសារព័ត៌មានស្ដីពី ការវាយតម្លៃសភាពការណ៍ទូទៅ ក្នុងថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឆ្នាំ២០០៩

នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) បានប្រកាសផ្សាយនៅក្នុងអង្គសន្និសីទសារព័ត៌មានថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះបានប្រព្រឹត្តទៅដោយដំណើរការល្អ និងគ្មានការតវ៉ាពីតំណាងគណបក្សនយោបាយ ដែលចូលរួមសង្កេតការណ៍នោះឡើយ ។

ឯកឧត្តម មាន សទិ សមាជិក គ.ជ.ប បានមានប្រសាសន៍ថា ការិយាល័យបោះឆ្នោតទាំង ១៩៣ នៅតាមបណ្ដាក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្តទូទាំងប្រទេស ត្រូវបានបើកដំណើរការជាធម្មតាតាមនីតិវិធីរបស់ គ.ជ.ប ។ ឯកឧត្តមបានឱ្យដឹងទៀតថា ការិយាល័យបោះឆ្នោតចំនួន ១៩១ ក្នុងចំណោមការិយាល័យ ១៩៣ បានចប់ការបោះឆ្នោតនៅម៉ោង ៩:៤៥ នាទីព្រឹក ហើយបានដំណើរការរាប់សន្លឹកឆ្នោតតាមនីតិវិធីរបស់ គ.ជ.ប ។ ការិយាល័យចំនួន ២ ត្រូវបានបិទនៅម៉ោង ៣ រសៀល ដោយសារអវត្តមានអ្នកបោះឆ្នោតចំនួន ២ នាក់ ។ ឯកឧត្តមបានបញ្ជាក់ថា អ្នកបោះឆ្នោតចំនួន ២ នាក់ ដែលជាប់ពិរុទ្ធ ហើយពុំទាន់មានសាលក្រមស្ថាពរ ដែល គ.ជ.ប បានស្នើសុំអន្តរាគមន៍ទៅក្រសួងយុត្តិធម៌ដើម្បីឱ្យបានទៅបោះឆ្នោតនោះ បានទៅបោះឆ្នោតតាមការិយាល័យរបស់ខ្លួនបានទាន់ពេលវេលា ។ អ្នកទាំង ២ នាក់នេះគឺឈ្មោះ ប៉ាក ទីភ៉ា នៅខេត្តកំពត និងឈ្មោះ ទូត សារ៉ន នៅខេត្តកំពង់ធំ ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា ក្នុងចំណោមអ្នកបោះឆ្នោតទាំង ១១.៣៥៣ នាក់ មានអ្នកបោះឆ្នោតចំនួន ៤ នាក់ ពុំបានចូលរួមបោះឆ្នោត ទី១ នៅខេត្តកំពង់ធំ ដោយសារទទួលមរណភាពកាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៩ ទី២ នៅខេត្តមណ្ឌលគិរី មានជំងឺ ហើយត្រូវទៅព្យាបាលនៅប្រទេសវៀតណាម ទី៣ នៅខេត្តតាកែវ គាត់ពុំស្ថិតនៅក្នុងប្រទេស និងទីបួន នៅរាជធានីភ្នំពេញ គាត់មិនចូលរួមបោះឆ្នោត ។ ឯកឧត្តមបានឱ្យដឹងទៀតថា លទ្ធផលបណ្ដោះអាសន្ននៅការិយាល័យបោះឆ្នោតនឹងធ្វើការប្រកាសនៅយប់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩ នេះតាមកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា ហើយតាមប្រតិទិនការងាររបស់ គ.ជ.ប លទ្ធផលផ្លូវការ នឹងប្រកាសនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ ។